ចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២៣ មានជនពិការចំនួន ១២.៨៨៧នាក់ រួមទាំងអ្នកនៅរស់រានជីវិតពីគ្រាប់មីន/ស.ផ.ស. ទទួលបានការស្តារលទ្ធភាពពលកម្មកាយសម្បទាពីមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាចំនួន ១១កន្លែង



ជួសជុលចំនួន ៣កន្លែង និងមជ្ឈមណ្ឌលព្យាបាលរបួសខួរឆ្អឹងខ្នងចំនួន ១កន្លែង។ ជំនួយគាំទ្រទាំងនោះរួមមាន៖ជើងសិប្បនិម្មិតចំនួន១.៧៩៦ជើង(អវយវៈក្រោមចំនួន១.៧២២ អវយវៈលើចំនួន៧៤) រណបចំនួន១.៣១៧ (អវយវៈក្រោម ១.២៦១ អវយវៈលើ ៣១ និងរណបដងខ្លួនចំនួន២៥) រទេះរុញចំនួន ៥២៩ (ក្នុងនោះ៤៩៧គ្រឿង សម្រាប់មនុស្សពេញវ័យ និង ៣២គ្រឿង សម្រាប់កុមារ) រទេះកង់បីចំនួន ២០គ្រឿង ឧបករណ៍ជំនួយការដើរចំនួន ២.២៦៧គ្រឿង និងបានជួសជុលគ្រឿងសិប្បនិម្មិតគ្រប់ប្រភេទចំនួន ៦.៩៨៩គ្រឿង។

ចាប់តាំងពីខែកក្កដា ឆ្នាំ២០២១ ដល់ខែមិថុនា ឆ្នាំ២០២៣ បណ្តាញស្ម័គ្រចិត្តជនរងគ្រោះបានធ្វើការស្រាវជ្រាវគុណភាពជីវិតទៅលើជនមានពិការភាពចំនួន៨.៥២៨នាក់(ស្ត្រីចំនួន ២.៨៣១នាក់) ក្នុងនោះមានជនរងគ្រោះដោយសារមីន និងស.ផ.ស.ចំនួន ៣.១២៦នាក់ (ស្ត្រីចំនួន ២៧១នាក់) នៅក្នុង ៦៨៦ភូមិ ៩៩ឃុំ/សង្កាត់ ២៥ស្រុក ក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យនិងប៉ៃលិន។លទ្ធផលនៃការស្រាវជ្រាវនេះត្រូវបានផ្សព្វផ្សាយចែករំលែកជាមួយនឹងភាគីពាក់ព័ន្ធក្នុងវិស័យពិការភាព ដើម្បីរៀបចំផែនការគាំទ្រជនមានពិការភាព។

## ៩. ការបញ្ជ្រាបយេនឌ័រ

ការបញ្ជ្រាបយេនឌ័រត្រូវបានយកចិត្តទុកដាក់គ្រប់រាល់សកម្មភាពក្នុងវិស័យមីននៅកម្ពុជា។ បច្ចុប្បន្នចំនួនបុគ្គលិកស្ត្រីមានប្រមាណ២៣%នៃបុគ្គលិកសរុបទាំងអស់ ដែលកំពុង ធ្វើការក្នុងវិស័យមីន។ វិស័យមីននៅកម្ពុជាគ្រោងនឹងបន្តបង្កើនចំនួនភាគរយនៃបុគ្គលិកស្ត្រីដែលបានចែងនៅក្នុងផែនការបញ្ជ្រាបយេនឌ័រក្នុងសកម្មភាពមីន ២០២១-២០២៥ និងគោលការណ៍



ណែនាំនានា។ ពាក់ព័ន្ធនឹងការបោសសម្អាតមីន អង្គភាពម៉ាពូ កំពុងខិតខំប្រឹងប្រែងបង្កើនការចូលរួមរបស់ស្ត្រីក្នុងដំណើរការរៀបចំផែនការនិងចាត់អាទិភាព ដើម្បីធានាតម្រូវការនិងអាទិភាពរបស់ស្ត្រីត្រូវបានយកចិត្តទុកដាក់។

## ១០.ការគ្រប់គ្រងគុណភាព

ប្រតិបត្តិករបោសសម្អាតមីនធ្វើសកម្មភាពត្រួតពិនិត្យដើម្បីធានាគុណភាព(QA) និងត្រួតពិនិត្យគុណភាព(QC)លើសកម្មភាពប្រតិបត្តិការរបស់ខ្លួន ដើម្បីធានាសុវត្ថិភាព ប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងការអនុវត្តសកម្មភាពមីន ព្រមទាំងធានាផ្ទៃដីដែលបោសសម្អាតរួចត្រូវបានប្រើប្រាស់តាមផែនការដែលបានគ្រោងទុក។



ជាមួយគ្នានេះ ក្រុមត្រួតពិនិត្យគុណភាពអាជ្ញាធរមីនក៏ធ្វើសកម្មភាពធានាគុណភាព(QA) និងត្រួតពិនិត្យគុណភាព(QC) បន្ថែម លើសកម្មភាពប្រតិបត្តិការរបស់ប្រតិបត្តិករ ដើម្បីពង្រឹងទំនុកចិត្តដល់ភាគីផ្តល់ជំនួយនិងអ្នកទទួលផលព្រមទាំងធានាសុវត្ថិភាពប្រតិបត្តិការ និងធានាដីបោសសម្អាតរួចត្រូវបានប្រើប្រាស់ស្របតាមស្តង់ដារកម្ចាត់មីនកម្ពុជា។ គិតចាប់ពីឆ្នាំ២០១៨ ដល់ ខែធ្នូ២០២៣ ក្រុមត្រួតពិនិត្យគុណភាពអាជ្ញាធរមីនបានធ្វើការត្រួតពិនិត្យចំនួន ១០.៣៦៥ លើក។

## ១១. ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន២០១៨-២០២៥

ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន២០១៨-២០២៥ ជាផែនទីតម្រង់ទិសសម្រាប់វិស័យមីននៅកម្ពុជា ដែលបានរៀបចំឡើងស្របតាមផែនការយុទ្ធសាស្ត្រជាតិ ព្រមទាំងបានឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្តក្នុងការអនុវត្តសេចក្តីប្រកាសម៉ាពូតូដែលជំរុញឱ្យរដ្ឋភាគីទាំងអស់បោសសម្អាតមីនឱ្យអស់ត្រឹមឆ្នាំ២០២៥។ ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន មានគោលបំណងរំដោះផ្ទៃដីដែលដឹងថាមានមីនឱ្យអស់ និងរំដោះផ្ទៃដីជាអាទិភាពដែលដឹងថាមានគ្រាប់បែកចង្កោមទាំងអស់ត្រឹមឆ្នាំ២០២៥ ព្រមទាំងដោះស្រាយបញ្ហាគំរាមកំហែងបណ្តាលមកពីស.ផ.ស.ផ្សេងទៀត។ដើម្បីធានាភាពជោគជ័យនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន អាជ្ញាធរមីនបានបន្តរៀបចំ និងអនុវត្តផែនការសកម្មភាព ៣ឆ្នាំ ២០១៨-២០២០។ ផ្អែកតាមរបាយការណ៍វាយតម្លៃ លើការអនុវត្តផែនការសកម្មភាពមីន ៣ឆ្នាំ វិស័យមីន នៅកម្ពុជាបានកៀរគរធនធានប្រមាណ ៦០% នៃផែនការតម្រូវការថវិកាដែលត្រូវបានប្រើប្រាស់សម្រាប់គោលបំណងចម្បងទាំង៣ក្នុងការរំដោះផ្ទៃដី ដែលដឹងថាមានមីននិងស.ផ.ស. ហើយសម្រេចបាន ៦៧% ធៀបនឹងផែនការ ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន។ បច្ចុប្បន្ននេះប្រតិបត្តិការសកម្មភាពមីន កំពុងត្រូវបានអនុវត្តតាមផែនការសកម្មភាពមីន ២០២១-២០២៣ នៃផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥។

## ១២. ការសម្របសម្រួលនិងគ្រប់គ្រងវិស័យមីន

ដើម្បីធានាការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងវិស័យមីនរាជរដ្ឋាភិបាលកម្ពុជាបានបង្កើតអាជ្ញាធរមីននៅឆ្នាំ២០០០ដែលមានតួនាទីនិងភារកិច្ចគ្រប់គ្រងសម្របសម្រួល និងត្រួតពិនិត្យរាល់សកម្មភាពមីនក្នុងប្រទេសកម្ពុជា។ បន្ថែមលើនេះរាជរដ្ឋាភិបាលកម្ពុជាបានបង្កើតក្រុមការងារចម្រុះរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍លើវិស័យមីននៅឆ្នាំ២០០៤ដែលជាយន្តការសម្របសម្រួលនិងពិគ្រោះយោបល់ក្នុងភាពជាដៃគូ ដែលមានការចូលរួមពីតំណាងក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ប្រតិបត្តិករបោសសម្អាតមីន និងអង្គការក្នុងវិស័យអភិវឌ្ឍន៍ ដើម្បីគាំទ្រសកម្មភាពមីន និងធានាសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ជាតិ។ ជាទូទៅ ក្រុមការងារបច្ចេកទេសចម្រុះនេះ ជួបប្រជុំចំនួន ២ដងក្នុងមួយឆ្នាំ។

## ១៣. ការគ្រប់គ្រងបរិស្ថានក្នុងសកម្មភាពមីន

នៅឆ្នាំ២០២១រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតស្តង់ដារកម្ចាត់មីនកម្ពុជាស្តីពីការគ្រប់គ្រងបរិស្ថានក្នុងសកម្មភាពមីន(លេខ២០)ព្រមទាំងបាននិងកំពុងបន្តពិភាក្សាដើម្បីកែសម្រួលបន្ថែម។


អាជ្ញាធរមីន
C.M.A.A

Phone: (+855) 23 880 462
Fax: (+855) 23 228 265

Address: New Building, Street 273&516,
Toul Sangker, Khan Russey Keo,
Phnom Penh, Cambodia

E-mail: info@cmaa.gov.kh
Website: www.cmaa.gov.kh


# អាជ្ញាធរមីន

អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន
និងសង្គ្រោះជនពិការដោយសារមីន

អាជ្ញាធរមីន
C.M.A.A

# ខិត្តប័ណ្ណព័ត៌មានសង្ខេបក្នុងវិស័យមីន

## នៅកម្ពុជា





## ១. សាវតា

គ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម(ស.ផ.ស.)នៅក្នុងប្រទេសកម្ពុជាជាលទ្ធផលនៃសង្គ្រាមជាបន្តបន្ទាប់ក្នុងប្រទេស និងក្នុងតំបន់ដែលបានអូសបន្លាយពេលយ៉ាងយូរ និងបានបង្កផលប៉ះពាល់ដល់ប្រទេសមួយនេះ ចាប់ពីដើមទសវត្សឆ្នាំ១៩៦០រហូតដល់ចុងឆ្នាំ១៩៩៨។ តំបន់ភាគពាយព្យនៃប្រទេសកម្ពុជាតាមបណ្តោយព្រំដែនប្រទេសថៃបានទទួលរងផលប៉ះពាល់ដោយសារការពង្រាយគ្រាប់មីនប្រឆាំងមនុស្សច្រើនជាងគេក្នុងពិភពលោក។ តំបន់ផ្សេងទៀត ជាពិសេសតំបន់ភាគខាងកើត បានទទួលរងផលប៉ះពាល់ដោយសារវត្តមាននៃស.ផ.ស.រាប់បញ្ចូលទាំងគ្រាប់បែកចង្កោមផងដែរ។អត្ថបទនេះគឺរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអំពីសមិទ្ធផលនៃវិស័យមីនចាប់ពីឆ្នាំ១៩៩២ ដល់ខែធ្នូ ឆ្នាំ២០២៣(នឹងមានការបញ្ជាក់បន្ថែមប្រសិនបើកាលបរិច្ឆេទ នៃទិន្នន័យខុសពីនេះ)។

WWW.CMAA.GOV.KH

## ២.ផលប៉ះពាល់នៃគ្រាប់មីន និងស.ផ.ស.

គ្រាប់មីន និងស.ផ.ស. បានសម្លាប់ និងបង្ករបួសដល់ប្រជាជននៅក្នុងប្រទេសកម្ពុជាចំនួន ៦៥.០៤៣នាក់ គិតចាប់តាំងពីឆ្នាំ១៩៧៩ មកដល់បច្ចុប្បន្ន។ ទោះបីជាចំនួនជនរងគ្រោះប្រចាំឆ្នាំត្រូវបានថយចុះពី ៤.៣២០នាក់ ក្នុងឆ្នាំ១៩៩៦ មកនៅត្រឹម ៤១នាក់ក្នុងឆ្នាំ២០២២ គ្រាប់មីន និងស.ផ.ស. នៅតែបន្តបង្កគ្រោះថ្នាក់ ដល់ប្រជាជននៅក្នុងប្រទេសកម្ពុជាជាពិសេសប្រជាជនដែលរស់នៅតាមតំបន់ជនបទ។ប្រសិនបើគិតពីខែមករាដល់ខែសឆ្នាំ២០២៣ ដល់ខែមីនា ឆ្នាំ២០២៤នេះ គឺមានចំនួនជនរងគ្រោះចំនួន ៣៨នាក់។ ក្នុងចំណោមជនរងគ្រោះទាំង នេះ ជនរងគ្រោះ ១១% បានស្លាប់បាត់បង់ជីវិត។




វត្តមានគ្រាប់មីន និងស.ផ.ស. ក៏បានបង្កជាឧបសគ្គក្នុងការស្តារ និងអភិវឌ្ឍប្រកបដោយសុវត្ថិភាព។គម្រោងអភិវឌ្ឍន៍សហគមន៍ស្ទើរតែទាំងអស់មិនអាចអនុវត្តបានដោយមិនមានការគាំទ្រពីការបោសសម្អាតមីននិងស.ផ.ស.បានឡើយ។សម្រាប់ប្រទេសមួយដែលរងផលប៉ះពាល់ ដូចជាប្រទេសកម្ពុជានេះ ការបោសសម្អាតគ្រាប់មីន និងស.ផ.ស. គឺជាឆ្អឹងខ្នងសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមសម្រាប់ប្រទេសជាតិ។

## ៣.ខឿនភាព និងបញ្ហាប្រឈម

សកម្មភាពមីនមនុស្សធម៌នៅកម្ពុជា បានចាប់ផ្តើមក្នុងឆ្នាំ១៩៩២។ គិតត្រឹមបច្ចុប្បន្ននេះ ប្រតិបត្តិករបោសសម្អាតមីន ក្នុងនោះរួមមាន CMAC, NPMEC, RCAF, HALO Trust, MAG,APOPO,CSHD,និងNPAបានរំដោះផ្ទៃដីដែលមានគ្រាប់មីននិងស.ផ.ស.បានសរុបចំនួន ៣.០២៤ គីឡូម៉ែត្រក្រឡា។ តារាងខាងក្រោមបង្ហាញអំពីគ្រាប់មីន និងស.ផ.ស. ដែលត្រូវបានរកឃើញ និងកម្ទេចចោលដោយក្រុមបោសសម្អាតផ្ទៃដី និងក្រុមឆ្លើយតបការកម្ទេចគ្រឿងផ្ទុះ៖






| | |
|---|---|
| មីនប្រឆាំងមនុស្ស | ១.១៧៩.៣៦៥ គ្រាប់ |
| មីនប្រឆាំងរថក្រោះ | ២៦.៣៣៩ គ្រាប់ |
| សំណល់ជាតិផ្ទុះពីសង្គ្រាម | ៣.១០៥.៥៩៣ គ្រាប់ |
| រាប់បញ្ចូលគ្រាប់បែកចង្កោម | |

គិតត្រឹមខែមិថុនា ឆ្នាំ២០២៣នេះ ប្រព័ន្ធទិន្នន័យថ្នាក់ជាតិបានបញ្ជាក់ថា ប្រទេសកម្ពុជានៅសល់ផ្ទៃដី ១.៣២១ គីឡូម៉ែត្រក្រឡាទៀត ដែលមានគ្រាប់មីន និងស.ផ.ស. ក្នុងនោះ

| | |
|---|---|
| ផ្ទៃដីមានមីន (គម²) | ៥៣៣ |
| ផ្ទៃដីមានគ្រាប់បែកចង្កោម (គម²) | ៧៣១ |
| ផ្ទៃដីមានស.ផ.ស (គម²) | ៥៩០ |



## ៤. ការរៀបចំផែនការ និងការចាត់អាទិភាព




នៅប្រទេសកម្ពុជា ការរៀបចំផែនការ និងចាត់អាទិភាពក្នុងការបោសសម្អាតគ្រាប់មីន និង ស.ផ.ស. ត្រូវបានធ្វើឡើងតាមរយៈការរួមបញ្ចូលគ្នានៃវិធីសាស្ត្រ«ពីលើចុះក្រោម» និង«ពីក្រោម ឡើងលើ»។ ក្នុងនាមស្ថាប័នគ្រប់គ្រង និងសម្របសម្រួលវិស័យមីន អាជ្ញាធរមីន បានរៀបចំបញ្ជីភូមិអាទិភាព សម្រាប់ការពង្រាយកម្លាំងបោសសម្អាតមីនដោយមានការ ប្រឹក្សាយោបល់ជាមួយអង្គភាពផែនការសកម្មភាពមីន (អង្គភាពម៉ាពូ) ប្រតិបត្តិករបោសសម្អាតមីន និងធ្វើការសិក្សាលើទិន្នន័យពាក់ព័ន្ធ ដែលនេះជាវិធីសាស្ត្រ«ពីលើចុះក្រោម»។បន្ទាប់ពីភូមិអាទិភាពត្រូវបានកំណត់រួចអង្គភាពម៉ាពូធ្វើការសហការជាមួយសហគមន៍ រងផលប៉ះពាល់ ប្រតិបត្តិករបោសសម្អាតមីន និងស្ថាប័នអភិវឌ្ឍន៍នានា ដើម្បីកំណត់ចម្ការមីនអាទិភាពសម្រាប់បោសសម្អាតប្រចាំឆ្នាំ ព្រមទាំងធានាថាតម្រូវការ និងអាទិភាព នៅក្នុងសហគមន៍ត្រូវបានគិតគូរ ដែលនេះជាវិធីសាស្ត្រ«ពីក្រោមឡើងលើ»។ វិធីសាស្ត្រទាំងពីរនេះគឺបំពេញឱ្យគ្នាទៅវិញទៅមក។

## ៥. ការចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

ផ្ទៃដីមានមីន និងស.ផ.ស. ដែលបានបោសសម្អាតរួច ៧៤% គឺត្រូវបានប្រើប្រាស់សម្រាប់វិស័យកសិកម្ម ចំណែកផ្ទៃដីនៅសល់ត្រូវបានប្រើប្រាស់ សម្រាប់សំណង់លំនៅដ្ឋាន ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការកាត់បន្ថយគ្រោះថ្នាក់ផ្សេងៗ។ ការបោសសម្អាតមីន និងស.ផ.ស. មានអ្នកទទួលផលផ្ទាល់និងប្រយោលចំនួន ១១.៩៨០.១៧២ នាក់ ដែលភាគច្រើនជាប្រជាជនដែលរស់នៅតំបន់ជនបទ។

## ៦.ប្រតិបត្តិការកម្ទេចគ្រឿងផ្ទុះ

ប្រតិបត្តិករបោសសម្អាតមីននៅប្រទេសកម្ពុជាមានសមត្ថភាពខ្ពស់ក្នុងការឆ្លើយតបចំពោះសំណើកម្ទេចគ្រឿងផ្ទុះដែលស្នើសុំ និងរាយការណ៍ពីសំណាក់អាជ្ញាធរមូលដ្ឋាន និងសហគមន៍ ដែលរងផលប៉ះពាល់។ ចាប់តាំងពីឆ្នាំ១៩៩២ ដល់ខែធ្នូ ឆ្នាំ២០២៣ ក្រុមកម្ទេចគ្រឿងផ្ទុះបានឆ្លើយតបសំណើចំនួន ១៨៧.៤០៩ករណី ព្រមទាំងបានរកឃើញ និងកម្ទេចចោលនូវគ្រាប់មីន និងស.ផ.ស. ចំនួន ១.៩១៧.២១៤គ្រាប់។

## ៧. ការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ស្ថាប័នចំនួន១០ បានចូលរួមក្នុងការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះនៅប្រទេសកម្ពុជា។ គោលបំណងការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ គឺដើម្បីធ្វើការអប់រំប្រជាជនឱ្យយល់ដឹងអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ និងសកម្មភាពដែលអាចបង្កឱ្យមានគ្រោះថ្នាក់ សំដៅឈានទៅផ្លាស់ប្តូរឥរិយាបថដែលបង្កហានិភ័យចំពោះប្រជាជន។ ការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ គឺជាការផ្តល់សារអប់រំដល់ប្រជាជន តាមរយៈបញ្ជ្រាបទៅក្នុងសកម្មភាពផ្សេងៗ ក្នុងវិស័យមីន ដូចជាការរំដោះផ្ទៃដីការប្រមូលទិន្នន័យគ្រោះថ្នាក់កិច្ចសង្គ្រោះជនរងគ្រោះនិងកម្មវិធីអប់រំសិក្សាថ្នាក់ជាតិផងដែរ។ ការងារអប់រំនេះ ត្រូវបានអនុវត្តតាមរយៈការផ្តល់វគ្គអប់រំផ្លូវការរួមទាំងការអប់រំតាមខ្នងផ្ទះនិងពិនិត្យប្រតិបត្តិការនៅទីវាលដោយផ្ទាល់សម្រាប់ក្រុមប្រជាជនដែលប្រឈមហានិភ័យខ្ពស់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។ ចាប់ពីឆ្នាំ២០១៨ ដល់ខែធ្នូ ឆ្នាំ២០២៣ ប្រជាជនចំនួន ៦.១៧៦.៣៦១ នាក់ បានទទួលការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ក្នុងនោះមានស្ត្រីចំនួន ២.៣១២.៤៤០នាក់ បុរស ២.២៣០.៣៤៨នាក់ កុមារី ៨០៣.៩៨២នាក់ និងកុមារា ៧៩៩.៨៨៦នាក់។

## ៨. កិច្ចសង្គ្រោះជនរងគ្រោះដោយសារមីន និងស.ផ.ស.

ប្រជាជនដែលនៅរស់រានមានជីវិតពីគ្រោះថ្នាក់និងគ្រួសារពួកគេត្រូវបានទទួលការយកចិត្តទុកដាក់ក្នុងការទទួលបាននូវសេវាកិច្ចសង្គ្រោះជនរងគ្រោះដែលបានកំណត់ក្នុងសកម្មភាពមីន ក្នុងនោះមានកិច្ចសង្គ្រោះបន្ទាន់ និងសេវាស្តារកាយសម្បទា ការគាំទ្រចិត្តសង្គម និងផ្លូវចិត្ត ការជំរុញការចូលរួមក្នុងសង្គមនិងសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន និងការស្វែងរកការគាំទ្រមតិ។

កិច្ចខិតខំប្រឹងប្រែងក្នុងការសង្គ្រោះជនរងគ្រោះគឺផ្តោតទៅលើវិធីសាស្ត្រពហុវិន័យដោយមានការចូលរួម ពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីបញ្ជ្រាបការងារកិច្ចសង្គ្រោះជនរងគ្រោះនេះចូលទៅក្នុងវិស័យផ្សេងៗ ដូចជា វិស័យសុខាភិបាល វិស័យពិការភាព វិស័យអប់រំ វិស័យការងារ វិស័យអភិវឌ្ឍន៍ និងយុទ្ធសាស្ត្រគាំពារសង្គមផ្សេងទៀត។

អាជ្ញាធរមីន កំពុងរៀបចំគោលការណ៍ណែនាំ សម្រាប់ស្ថាប័នអនុវត្តការងារសង្គ្រោះជនរងគ្រោះដោយសារមីន និងស.ផ.ស. និងបានបញ្ចប់ស្តង់ដារសកម្មភាពកម្ចាត់មីនស្តីពីកិច្ចសង្គ្រោះជនរងគ្រោះដោយសារមីននិងស.ផ.ស.ព្រមទាំងសហការជាមួយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ដើម្បីធ្វើការស្រាវជ្រាវគុណភាពជីវិត ក្រោមការគាំទ្រគម្រោងបោសសម្អាតមីនដើម្បីលទ្ធផលជំណាក់កាលទី៤។